| ៣៦-លោក | ជ្រុន លឹមគា | ប្រធានរោងចក្រភូមិព្រែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៣៧-លោក | កន សុជាតិ | ប្រធានរោងចក្រចំការមន នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៣៨-លោក | ឈុន វិចិត្រ | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៣៩-លោក | ផុន ធឿន | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤០-លោក | អ៊ីវ ឈុនកេង | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤១-លោកស្រី | ហ៊ុយ សៅខោរ | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |

| | | |
|---|---|---|
| ៤២-លោកស្រី | ចាន់ ទៀង | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៣-លោក | សៅ ដារ៉ា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៤-លោក | សុខ ហ្សេនី | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៥-លោកស្រី | ស៊ឹម ផល | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៦-លោក | ដា វដ្ឋារ៉ា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៧-លោក | ព្រុំ ចាន់ណារី | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៨-លោក | ជិន សុវត្ថារ៉ា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤៩-លោកស្រី | យ៉ាន រីណា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥០-លោក | សេង វេយាណុង | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥១-លោក | ព្រៃ ច័ន្ទរស្មី | អនុប្រធានរោងចក្រភូមិព្រែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥២-លោកស្រី | ផៃ ផាលីន | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៣-លោក | យឹម សេង | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៤-លោកស្រី | នាង សុភី | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៥-លោកស្រី | ម៉ៅ អមរា | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៦-លោក | ប៊ុក ងួន | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៧-លោក | ឈឹម សុផល | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៨-លោក | ព្រុំ វន | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥៩-លោកស្រី | ព្រុំឌុច ប៉ូរ៉ាណារ័ត្ន | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦០-លោក | សំ ដារ៉ា | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦១-លោក | ធឹម ធឿន | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦២-លោក | គ្រី សុខា | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៣-លោកស្រី | ទិត្យ គីមហួត | ប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៤-លោកស្រី | តូ តូចចិន្តា | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៥-លោក | អ៊ុង រ័ត្ន | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៦-លោកស្រី | ម៉ៅ មករា | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៧-លោកស្រី | ប៉ែន ផល្លា | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៨-លោកស្រី | អ៊ឹម ចិន្តា | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦៩-លោក | ស៊ឺ សៅ | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧០-លោក | ឯម ទីតូ | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧១-លោក | ចឹក មាឃ | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧២-លោកស្រី | អួន សាណារ៉ា | អនុប្រធានផ្នែក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៣-លោក | ពៅ ស៊ីវណ្ណា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៤-លោក | ប៊ុក ហៃល | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៥-លោក | ស្អាន រ៉ូសាលី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៦-លោក | ទៀវ វីរៈ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៧-លោក | នួន ឌី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧៨-លោក | ប្រាក់ សុភិន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |

| | | |
|---|---|---|
| ៧៩-លោក | សេង ហុក | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨០-លោក | ឱក គីមហួត | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨១-លោក | ទុំ វុឌ្ឍ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨២-លោក | អៀម សុវណ្ណលី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៣-លោក | ហោ សែ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៤-លោក | អ៊ិន គា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៥-លោក | ជាម ស៊ាងហុង | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៦-លោក | នូ ប៊ុណ្ណា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៧-លោក | គិត ឡា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៨-លោកស្រី | កែវ ចន្ថា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨៩-លោក | លុយ ចន្ទី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩០-លោក | ហ៊ិន ភាព | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩១-លោក | ហួត ធៀង | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩២-លោក | អ៊ឹម វុទ្ធី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៣-លោក | ឃុំ សុភ័ក្ត្រ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៤-លោក | សាត់ សាម៉ន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៥-លោក | ហ៊ុយ សុគន្ធី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៦-លោក | សន លេញ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៧-លោក | ផន ណាង | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៨-លោក | ផេង គុហេង | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩៩-លោកស្រី | សេក សុខុន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០០-លោក | ណាប សុខឡាយ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០១-លោក | អ៊ុក ធូ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០២-លោក | ឈឹម ម៉ាលីន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៣-លោក | ឡាច សាយ | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៤-លោក | ប៊ី ដា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៥-លោក | ត្រឡុង បូរី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៦-លោក | មាស មុន្នី | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៧-លោក | ហែម សុភឿន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៨-លោក | អ៊ា យឿន | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០៩-លោក | គីម សំណាង | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១០-លោក | យិន សេដ្ឋា | ប្រធានក្រុម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១១-លោកស្រី | ម៉ា ច័ន្ទបុប្ផា | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១២-លោកស្រី | ជ្រុន សៀកលី | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៣-លោកស្រី | ហ៊ិត គីមយី | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៤-លោកស្រី | ហួន សុជាតិ | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៥-លោកស្រី | ម៉ែន សុន្ទរី | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |

| | | |
|---|---|---|
| ១១៦-លោកស្រី | សួស សុភាព | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៧-លោកស្រី | បាន សុម៉ាលី | បេឡាការិនី នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៨-លោកស្រី | ស៊ឹម ចន្ទី | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១៩-លោក | យិន ម៉ុន | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២០-លោក | អ៊ែ ណាង | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២១-លោក | ហេង រតនា | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២២-លោកស្រី | យ៉ុង នីណា | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៣-លោក | យ៉ឹម សុនឌឿន | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៥-លោក | ខឹម លឹម | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៥-លោកស្រី | តូ តូចនីរីណា | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៦-លោក | ជា ជន់ | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៧-លោក | នូ សារ៉េន | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៨-លោក | ប្រាក់ ជោតិនិស្សិត | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២៩-លោក | លូ ជីវ័ន្ត | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣០-លោក | ឈុន វ៉ាន់ថា | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣១-លោក | ញ៉ា រិទ្ធុង | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣២-លោក | គង់ ផុន | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៣-លោក | នាង ឡូញ | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៤លោក | សុក សុភ័ណ្ណារ៉េត | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៥-លោក | ឡុង សាវ៉ុន | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៦-លោក | ងិន វ៉េង | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៧-លោក | សេង តារា | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៨-លោក | នូ សំអឿន | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៣៩-លោក | ស៊ិន វុទ្ធី | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤០-លោក | ស៊ុន សារុំ | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤១-លោក | មូល សំអាត | ភ្នាក់ងារអានលេខ-ចែកវិក្កយប័ត្រ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤២-លោក | លី អឿន | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៣-លោក | ពេជ្រ អុន | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៤-លោក | ឈឹម សារី | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៥-លោក | កែវ មុត | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៦-លោក | ជិន សម្បត្តិ | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៧-លោក | ស៊ឹម សុខុន | និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១៤៨-លោកស្រី | ឡោ គីមឡាយ | ប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៤៩-លោក | សោម ពេជ្រ | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥០-លោក | សោម សីហា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥១-លោកស្រី | ហេង ចេស្តា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |

| | | |
|---|---|---|
| ១៥២-លោក | ផេង ប៊ុនហ៊ី | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៣-លោកស្រី | ម៉ា ចិន្ត្រា | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៤-លោកស្រី | ស៊ាង វ៉ានី | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៥-លោក | នាក់ វីរៈ | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៦-លោកស្រី | ខូវ សុខល័ក្ខ | អនុប្រធានការិយាល័យ នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៧-លោក | ប៊ុក ប៊ុច | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៨-លោក | ម៉ាក គ្រីឌី | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៥៩-លោក | សែម យ៉ុង | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦០-លោកស្រី | ឈាង ប៊ូឡែន | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦១-លោកស្រី | ម៉ាក លក្ខិណា | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦២-លោក | ញ៉ុត ទី | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៣-លោក | ប៉ាន់ បូ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៤-លោក | ដឿយ ស៊ីដូរ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៥-លោក | ឡោ ហង់ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៦-លោក | ទឹម វណ្ណៈ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៧-លោក | គឿន សុគី | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៨-លោក | គៃ ធុល | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៦៩-លោក | ដឿម ជា | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧០-លោក | ម៉ូត សាម៉េត | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧១-លោក | ភឿត សុធា | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧២-លោក | ខិត សាវ៉ាត់ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៣-លោក | ដឿយ ស៊ីដេត | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៤-លោក | ទៀង សិលាមុនី | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៥-លោក | សឿន សល់ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៦-លោក | សុខ វ៉ង | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៧-លោក | ឌឹក សាដាំ | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៨-លោក | ម៉ោង គិមស៊ីន | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១៧៩-លោក | ភន់ ប្រុក | និយោជិត នៃរដ្ឋាករទឹកស្វយ័តសៀមរាប |

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១២ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ ស.សរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**-

ត្រូវបានតែងតាំង ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកណ្ដាល ជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកណ្ដាល ។

**ប្រការ២.**-

បទបញ្ញត្តិទាំងឡាយណាមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣.**-

រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលខេត្តកណ្ដាល និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ១៣ កើត ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

តមកពីរាជកិច្ចលេខ ១៩

លេខ ធ៧-០១៧-៣០៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើ
# វិធាននិងនីតិវិធី Cambodian Shared Switch

# ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធី Cambodian Shared Switch" ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះដើម្បីជាមូលដ្ឋាននៃការអនុវត្តការផាត់ទាត់



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

និងទូទាត់តាមរយៈប្រព័ន្ធ Cambodian Shared Switch ដែលបម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងប្រព័ន្ធ Cambodian Shared Switch នៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅផ្តល់ព័ត៌មានលម្អិតអំពីប្រតិបត្តិការប្រព័ន្ធ Cambodian Shared Switch ផ្តល់ការណែនាំអំពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកនីមួយៗ និងដំណើរការដំណោះស្រាយបណ្តឹង។ "វិធាននិងនីតិវិធី Cambodian Shared Switch" នេះជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកប្រព័ន្ធ Cambodian Shared Switch។

**ប្រការ ៣.-**

ប្រកាសនេះអនុវត្តចំពោះគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ អគ្គបេឡា ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល ៖**
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន ៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.
វិធាននិងនីតិវិធី
Cambodian Shared Switch
CSS
ATM
ឧបសម្ព័ន្ធប្រកាសលេខ ធ១៤-០១៧-៣០៧ ប្រ.ក
ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៧

## ឧបសម្ព័ន្ធ៤ - ទម្រង់កិច្ចសន្យាស្តីពី សេវាសភាផាត់ទាត់ជាតិ

# កិច្ចសន្យា
# ស្តីពី
# "សេវាសភាផាត់ទាត់ជាតិ"

កិច្ចសន្យានេះធ្វើឡើងរវាង "សភាផាត់ទាត់ជាតិ" ដែលមានអាសយដ្ឋាន ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ តំណាងដោយឈ្មោះ.......................................... និងគ្រឹះស្ថាន.......................(គ្រឹះស្ថានធនាគារ/គ្រឹះស្ថានហិរញ្ញវត្ថុ) តទៅហៅថា "សមាជិក" ដែលមានអាសយដ្ឋាន..................................................តំណាងដោយឈ្មោះ........................ ។

ដើម្បីឲ្យការអនុវត្តរបស់សភាផាត់ទាត់ជាតិមានរបៀបរៀបរយល្អ ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមលក្ខខណ្ឌ និងខចែងដូចខាងក្រោម ៖

**ប្រការ១ - គោលបំណង**

កិច្ចសន្យាសេវារវាងសភាផាត់ទាត់ជាតិ និងសមាជិកកំណត់កម្រិតគោលដែលត្រូវសម្រេច និងជាក្របខ័ណ្ឌសម្រាប់វាស់វែងការអនុវត្តដែលជាឧបករណ៍គ្រប់គ្រងទូទៅមួយសម្រាប់ភាគីទាំងអស់ ។ កិច្ចសន្យាសេវានេះ គឺសម្រាប់វាយតម្លៃអំពីការអនុវត្តចំពោះសេវា មធ្យោបាយ និងរាល់ដំណើរការដែលមានចែងក្នុង "**វិធាននិងនីតិវិធី CSS**" ។

**ប្រការ២ - ការវាស់វែងការអនុវត្ត**

សភាផាត់ទាត់ជាតិនិងសមាជិកទាំងអស់នឹងអនុវត្តនិងរក្សាកម្រិតស្តង់ដាររបស់សភាផាត់ទាត់ជាតិដើម្បីឲ្យការអនុវត្តសម្រេចបាន ៩៥% (កៅសិបប្រាំភាគរយ) នៃរង្វាស់គោល ១០០% (មួយរយភាគរយ) ។ ការអនុវត្តប្រចាំថ្ងៃ ត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃ ដូចខាងក្រោម ៖

- ពេលវេលាផាត់ទាត់និងទូទាត់ជាក់ស្តែង ៨០%
- ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ ៥%
- ម៉ោងឈប់ទទួល Input ៥%
- ពេលវេលាទូទាត់ជាក់ស្តែង ៥%
- បញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី ៥% ។

**ប្រការ៣ - លក្ខខណ្ឌ និងខចែង**

កិច្ចសន្យាសេវាសភាផាត់ទាត់ជាតិនេះ ជាចំណងផ្លូវច្បាប់របស់ភាគីទាំងពីរ ប៉ុន្តែមិនមានការពិន័យ ឬដំណោះស្រាយជាហិរញ្ញវត្ថុទេ ប្រសិនបើការអនុវត្តមិនអាចសម្រេចបានតាមគោលដៅ ។ ភាគីពាក់ព័ន្ធអាចពិភាក្សាដើម្បីកែប្រែកិច្ចសន្យាសេវានេះដោយត្រូវមានការឯកភាពពីសភាផាត់ទាត់ជាតិ ។

ភាគីទាំងពីរបានព្រមព្រៀងអនុវត្តតាមខ្លឹមសារដែលមានចែងខាងលើ ។

**ប្រការ៤- ប្រសិទ្ធភាពអនុវត្ត**

កិច្ចសន្យានេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០.....

**តំណាងធនាគារជាតិនៃកម្ពុជា**
**អគ្គនាយកបច្ចេកទេស**

**តំណាងគ្រឹះស្ថានជាសមាជិក**
...........................

.......................................

..................................

**ឧបសម្ព័ន្ធ៥ - ពាក្យស្នើសុំចូលជាសមាជិកសភាផាត់ទាត់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំចូលជាសមាជិកសភាផាត់ទាត់ជាតិ**

ឈ្មោះគ្រឹះស្ថានធនាគារ/គ្រឹះស្ថានហិរញ្ញវត្ថុ:.................................................................................
ឈ្មោះអ្នកស្នើសុំ :.................................................................................
ឋានៈ :.................................................................................
អាសយដ្ឋានគ្រឹះស្ថាន :.................................................................................
អាសយដ្ឋានប្រៃសណីយ៍:.................................................................................
ទូរស័ព្ទ :.................................................................................

**សូមគោរពជូន**
**លោកជំទាវអគ្គនាយកបច្ចេកទេស និងជាប្រធានគណៈកម្មាធិការ**
**ប្រតិបត្តិការសភាផាត់ទាត់ជាតិ**

ក្រោយពីបានស្វែងយល់ ៖

- ប្រកាសលេខធ.៥.០០.១៧០ ប្រ.ក. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល
- ប្រកាសលេខធ.៥.០០.១៥០ ប្រ.ក. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០០ ស្ដីពីសភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក
- ប្រកាសលេខធ.១៤.០១៦.១៤៧ ប្រ.ក. ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីសមាជិកភាពប្រព័ន្ធ FAST និងប្រព័ន្ធ Central Shared Switch
- ប្រកាសលេខធ.១៤.០១៦.១៣៥ ប្រ.ក. ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការដាក់ឲ្យប្រើវិធាននិងនីតិវិធី សផាភាត់ទាត់ជាតិ
- ប្រកាសលេខធ.១៤.០១៧.៣០៧ ប្រ.ក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការដាក់ឲ្យប្រើវិធាននិងនីតិវិធីប្រព័ន្ធ Cambodian Shared Switch ។

យើងខ្ញុំសុំស្នើលោកជំទាវមេត្តាពិនិត្យនិងអនុញ្ញាតឱ្យគ្រឹះស្ថាន...........................បានចូលជាសមាជិកសភាផាត់ទាត់ជាតិ ដើម្បីសម្រួលដល់ការទូទាត់និងផាត់ទាត់មូលប្បទានបត្រ ប័ណ្ណ

និង/ឬ ឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក រវាងគ្រឹះស្ថានយើងខ្ញុំជាមួយនិងគ្រឹះស្ថានដទៃទៀត ។ យើងខ្ញុំស្នើសុំប្រើប្រាស់ប្រព័ន្ធខាងក្រោម ៖

☐ ប្រព័ន្ធផាត់ទាត់ជាតិ ☐ ប្រព័ន្ធទូទាត់រាយភ្លាមៗ ☐ ប្រព័ន្ធ CSS

☐ Stand-alone Client Module ☐ Shared Client Module

យើងខ្ញុំសន្យាអនុវត្តតាមយ៉ាងម៉ឺងម៉ាត់នូវវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ពាក់ព័ន្ធនឹងការទូទាត់ និងបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា ។

សូមលោកជំទាវ ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ...........ខែ ........... ឆ្នាំ២០

**ហត្ថលេខា និងត្រា**

សូមជូនភ្ជាប់ជាមួយនូវៈ

- ច្បាប់ថតចម្លងនៃអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ១ ច្បាប់
- លិខិតឧទ្ទេសនាម និងគំរូហត្ថលេខាតំណាងចូលរួមផាត់ទាត់ ១ ច្បាប់
- កិច្ចសន្យាផ្តល់ឥណទានវិបារូបន៍ ១ ច្បាប់
- លិខិតស្នើសុំបើកគណនីទូទាត់នៅធនាគារជាតិ ១ ច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំទទួលយកសមាជិកមិនផ្ទាល់នៃប្រព័ន្ធ CSS**

ឈ្មោះគ្រឹះស្ថានធនាគារ/ ហិរញ្ញវត្ថុ : .......................................................................................
ឈ្មោះអ្នកស្នើសុំ : .......................................................................................
ឋានៈ : .......................................................................................
អាសយដ្ឋានគ្រឹះស្ថាន : .......................................................................................
អាសយដ្ឋានប្រៃសណីយ៍ : .......................................................................................
ទូរស័ព្ទ : .......................................................................................

**សូមគោរពជូន**
**លោកជំទាវអគ្គនាយកបច្ចេកទេស និងជាប្រធានគណៈកម្មាធិការ**
**ប្រតិបត្តិការសភាផាត់ទាត់ជាតិ**

**កម្មវត្ថុ:** ការស្នើសុំទទួលយកធនាគារ/គ្រឹះស្ថាន.....................................ជាសមាជិកមិនផ្ទាល់នៃប្រព័ន្ធ CSS ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំតំណាង....................សូមអនុញ្ញាតជម្រាបជូនលោកជំទាវមេត្តាជ្រាបថាដើម្បីសម្រួលដល់ការទូទាត់ប័ណ្ណយើងខ្ញុំស្នើសុំទទួលយកធនាគារ/គ្រឹះស្ថាន.........ជាសមាជិកមិនផ្ទាល់នៃប្រព័ន្ធ CSS ។ ធនាគារ/គ្រឹះស្ថាន........... និងគ្រឹះស្ថានរបស់យើងខ្ញុំបានឯកភាពចុះកិច្ចព្រមព្រៀងក្នុងការទទួលយកធនាគារ/គ្រឹះស្ថាន..........ធ្វើជាសមាជិកមិនផ្ទាល់ ដោយគ្រឹះស្ថានយើងខ្ញុំស្ម័គ្រចិត្តធានាការទូទាត់នូវកាតព្វកិច្ចផាត់ទាត់ប្រចាំថ្ងៃ និងបង់កម្រៃសេវានានាពាក់ព័ន្ធនឹងប្រតិបត្តិការផាត់ទាត់ជួស ធនាគារ/គ្រឹះស្ថាន ........... ។

យើងខ្ញុំសន្យាអនុវត្តតាមយ៉ាងម៉ឺងម៉ាត់នូវកិច្ចព្រមព្រៀងប្រកាស និងបទប្បញ្ញត្តិនានា ពាក់ព័ន្ធនឹងសភាផាត់ទាត់ជាតិ ។

យើងខ្ញុំសូមជូនភ្ជាប់ជាមួយនូវ៖

- ច្បាប់ចំតចម្លងនៃអាជ្ញាប័ណ្ណធនាគារ/គ្រឹះស្ថាន ......... ១ច្បាប់
- កិច្ចព្រមព្រៀងរវាងធនាគារ/គ្រឹះស្ថានរបស់យើងខ្ញុំ និងធនាគារ/គ្រឹះស្ថាន.........ជាសមាជិកមិនផ្ទាល់ ១ច្បាប់

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកជំទាវមេត្តាអនុញ្ញាតឲ្យធនាគារយើងខ្ញុំទទួលធនាគារ/គ្រឹះស្ថាន............ជាសមាជិកមិនផ្ទាល់នៃប្រព័ន្ធ CSS ដោយអនុគ្រោះ ។

សូមលោកជំទាវទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ...........ខែ ........... ឆ្នាំ២០

**អគ្គនាយក/នាយក**
**ហត្ថលេខានិងត្រា**

## ឧបសម្ព័ន្ធ៦ - របាយការណ៍

បញ្ជីឈ្មោះរបាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃសម្រាប់សភាជាត់ទាត់មាននៅក្នុងតារាងខាងក្រោម ។

| ល.រ | លេខកូដ | ឈ្មោះរបាយការណ៍ | ការពិពណ៌នា |
|---|---|---|---|
| ១ | CSSR-001 | ប្រព័ន្ធ CSS - របាយការណ៍ប្រតិបត្តិការលម្អិតរបស់ប្រព័ន្ធ CSS | ផ្ទុកព័ត៌មានលម្អិតនៃគ្រប់ប្រតិបត្តិការដែលធ្វើឡើងដោយប្រព័ន្ធ CSS |
| ២ | CSSR-002 | ប្រព័ន្ធ CSS - របាយការណ៍ប្រតិបត្តិការលម្អិតរបស់សមាជិក | ផ្ទុកព័ត៌មានលម្អិតនៃរាល់ប្រតិបត្តិការរបស់ធនាគារដែលជាសមាជិក |
| ៣ | CSSR-003 | ប្រព័ន្ធ CSS - របាយការណ៍ការទូទាត់ចំនួនប្រាក់ប្រតិបត្តិការសម្រាប់សមាជិក | ផ្ទុកព័ត៌មានលម្អិតនៃការទូទាត់ប្រតិបត្តិការ (ចំពោះចំនួនប្រាក់នៃប្រតិបត្តិការប៉ុណ្ណោះ) |
| ៤ | CSSR-004 | ប្រព័ន្ធ CSS - របាយការណ៍ការទូទាត់កម្រៃប្រតិបត្តិការសម្រាប់សមាជិក | ផ្ទុកព័ត៌មានលម្អិតនៃការទូទាត់ប្រតិបត្តិការ (ចំពោះតែកម្រៃប៉ុណ្ណោះ) |
| ៥ | CSSR-005 | ប្រព័ន្ធ CSS - របាយការណ៍ប្រតិបត្តិការមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធសមាជិក | ផ្ទុកព័ត៌មានលម្អិតនៃប្រតិបត្តិការដែលមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធសមាជិក |
| ៦ | CSSR-006 | ប្រព័ន្ធ CSS - របាយការណ៍ប្រតិបត្តិការមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធ ISS នីមួយៗ | ផ្ទុកព័ត៌មានលម្អិតនៃប្រតិបត្តិការដែលមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធសមាជិកមួយក្នុងចំណោម ISS ទាំងអស់ |
| ៧ | CSSR-007 | ប្រព័ន្ធ CSS - របាយការណ៍ប្រតិបត្តិការមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធ ACQ | ផ្ទុកព័ត៌មានលម្អិតនៃប្រតិបត្តិការដែលមិនស៊ីគ្នារវាងប្រព័ន្ធ CSS និងប្រព័ន្ធ ACQ |
| ៨ | CSSR-008 | ប្រព័ន្ធ CSS - របាយការណ៍ពីប្រតិបត្តិការមិនជោគជ័យរបស់ប្រព័ន្ធ CSS | ផ្ទុកព័ត៌មានលម្អិតនៃរាល់ប្រតិបត្តិការដែលមិនជោគជ័យនៅពេលដែលដំណើរការនៅប្រព័ន្ធ CSS |
| ៩ | CSSR-009 | ប្រព័ន្ធ CSS - របាយការណ៍អំពីចំនួនប្រាក់និងកម្រៃសម្រាប់ ISS | ផ្ទុកព័ត៌មានលម្អិតនៃចំនួនប្រាក់សរុបរបស់ប្រតិបត្តិការសរុប/ទាំងអស់ និងកម្រៃសរុបសម្រាប់ ISS |

| | | | |
|---|---|---|---|
| ១០ | CSSR-010 | ប្រព័ន្ធ CSS - របាយការណ៍អំពីចំនួនប្រាក់និងកម្រៃសម្រាប់ ACQ | ផ្ទុកព័ត៌មានលម្អិតនៃចំនួនប្រាក់សរុបរបស់ប្រតិបតិការសរុប/ទាំងអស់ និងកម្រៃសរុបសម្រាប់ ACQ |
| ១១ | CSSR-011 | ប្រព័ន្ធ CSS - របាយការណ៍សង្ខេបនៃកម្រៃតាមប្រភេទប្រតិបត្តិការ | ផ្ទុកព័ត៌មានលម្អិតនៃកម្រៃរបស់ប្រតិបត្តិការសរុប/ទាំងអស់ សម្រាប់ ISS/ACQ |
| ១២ | CSSR-012 | ប្រព័ន្ធ CSS - របាយការណ៍សង្ខេបអំពីការទូទាត់សម្រាប់គ្រប់សមាជិក | ផ្ទុកព័ត៌មានលម្អិតនៃចំនួនទឹកប្រាក់ដែលបានទូទាត់សរុបសម្រាប់គ្រប់សមាជិក |
| ១៣ | CSSR-013 | ប្រព័ន្ធ CSS - របាយការណ៍សង្ខេបអំពីការទូទាត់សម្រាប់សមាជិកនីមួយៗ | ផ្ទុកព័ត៌មានលម្អិតនៃចំនួនប្រាក់ដែលបានទូទាត់សរុបសម្រាប់សមាជិកនីមួយៗ |

## ឧបសម្ព័ន្ធ៧ - ហេដ្ឋារចនាសម្ព័ន្ធ និងសុវត្ថិភាពរបស់ប្រព័ន្ធ CSS

ប្រព័ន្ធ CSS មានបទដ្ឋានផ្នែកបច្ចេកទេស និងធុរកិច្ច ដូចខាងក្រោម៖

### ១. បណ្តាញទំនាក់ទំនង (TCP/IP Protocol )

បណ្តាញទំនាក់ទំនងគ្រប់គ្រង Port និង Protocol ផ្អែកលើ TCP/IP ដែលតភ្ជាប់ជារូបវន្តរវាង Network Formatter ឬឧបករណ៍ប្រព័ន្ធ Server ។

### ២. Formatter (ISO 8583)

**Formatter** ត្រូវបានប្រើប្រាស់ក្នុងការបម្លែងសារ Input (ឧទាហរណ៍ ៖ ទម្រង់សារខាងក្រៅនៃប្រព័ន្ធ ឬឧបករណ៍របស់សមាជិក) ទៅជាទម្រង់សារខាងក្នុងសម្រាប់ម៉ូឌុលស្នូល (Shared Cash) នៃប្រព័ន្ធ CSS ។ Shared Cash (SHC) ប្រើប្រាស់ Formatter ដើម្បីធ្វើការបម្លែងទៅជាទម្រង់សារខាងក្រៅ ( ISO 8583) សម្រាប់សមាជិក និងបណ្តាញប្រើប្រាស់ ។ លក្ខណៈទម្រង់សារ ISO ស្តង់ដាររួមសម្រាប់ប្រព័ន្ធ CSS មានចែងនៅក្នុងឯកសារ CSS ISO 8583 **"Message Format and Flow"** ។ ទម្រង់សារ ISO ស្តង់ដាររួម កំណត់នូវប្រភេទប្រតិបត្តិការ ATM និង POS និងប្រភេទសារ បណ្តាញ ។

### ៣. ម៉ូឌុលស្នូល Shared Cash

**Shared Cash** (SHC) គឺជាម៉ូឌុលស្នូលដែលធ្វើប្រតិបត្តិការបញ្ជូនបែងចែកសារ (Message Switching) សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធ CSS ។ ប្រព័ន្ធនេះគ្រប់គ្រងការផ្ទៀងផ្ទាត់អត្តសញ្ញាណ ការអនុញ្ញាត ការបញ្ជូនបែងចែក និងកត់ត្រាកំណត់ត្រានៃសារប្រតិបត្តិការដែលប្រព័ន្ធ CSS ទទួលបាន ព្រមទាំងបង្កើតជាសារឆ្លើយតបទៅ ISS ។ SHC សម្របសម្រួលលំដាប់លំដោយនៃសាររបស់ប្រតិបត្តិការ ដោយដើរតួនាទីជាអន្តរការីរវាងសមាជិកនៅពេលដែលអ្នកកាន់ប័ណ្ណធ្វើប្រតិបត្តិការនៅលើ ATM / POS របស់សមាជិកមួយផ្សេងទៀត ។

### ៤. ម៉ូឌុលសុវត្ថិភាព

**Hardware Security Module (HSM)** គឺជាឧបករណ៍សុវត្ថិភាពដាច់ដោយឡែកមួយដែលការពារការជ្រៀតចូលដូចជា Wiretapping, Program Modification និង Physical Machine Break-ins ។ ឧបករណ៍នេះមានមុខងារបម្លែងកូដទិន្នន័យដើម្បីធានាសុវត្ថិភាពក្នុងបណ្តាញនិងរវាងប្រព័ន្ធ ។ HSM ជាទីកន្លែងសុវត្ថិភាពក្នុងការរៀបចំ និងបង្កើតកូនសោសុវត្ថិភាព ។ ឧបករណ៍នេះអាចបង្កើត ផ្ទៀងផ្ទាត់ បកប្រែ និងបម្លែងកូដចំពោះកូនសោសុវត្ថិភាព ។

### ៥. ម៉ូឌុល Store-and-Forward

ប្រព័ន្ធ CSS មានសមត្ថភាពរក្សាទុក និងបញ្ជូនបន្ត **"Store and Forward"** (SAF) ។ ប្រតិបត្តិការដែលត្រូវរក្សាទុក និងបញ្ជូនបន្តដូចជា Reverse និងប្រតិបត្តិការដែលត្រូវបានអនុញ្ញាតដោយប្រព័ន្ធ ត្រូវបានផ្ទុកនៅក្នុង File SAF ។ ប្រព័ន្ធ CSS ផ្តល់នូវមុខងារ SAF Relay ដែលបញ្ជូន

បន្តប្រតិបត្តិការដែលផ្ទុកនៅក្នុង File SAF របស់សមាជិក ។ នៅក្នុង File SAF នេះមានប្រតិបត្តិការ (ដូចជា 01xx, 02xx, 04xx, 05xx និង Internal 0270) ដែលបានអនុញ្ញាតដោយ SHC និងកត់ត្រាចូលទៅក្នុង File SAF របស់សមាជិកក្នុងពេលដំណើរការ SAF ។ ប្រតិបត្តិការទាំងនេះនឹងនៅក្នុង File SAF រហូតដល់ពេលប្រព័ន្ធ CSS ធ្វើ SAF Relay ហើយសារប្រតិបត្តិការក៏ត្រូវបានបញ្ជូនទៅប្រព័ន្ធរបស់សមាជិកដើម្បីចុះប្រតិបត្តិការ ។

**៦. ម៉ូឌុល Monitor**

ម៉ូឌុល Monitor គឺជាកម្មវិធីពេញលេញមួយដែលផ្តល់ជាច្រកតែមួយសម្រាប់អ្នកប្រើប្រាស់ធ្វើការតាមដាននូវដំណើរការទាំងមូលក្នុងប្រព័ន្ធ CSS ។ កម្មវិធីនេះ ផ្តល់ការទ្រទ្រង់កំណត់ផ្នែកផ្សេងៗក្នុងការតាមដានដំណើរការនៃប្រព័ន្ធ CSS និងមានមុខងារដូចខាងក្រោម ៖

- ស្ថានភាពការទំនាក់ទំនង
- ស្ថានភាពរបស់សមាជិក
- ស្ថិតិនៃសារ និងភាពរអាក់រអួល
- ស្ថានភាពប្រអប់សារ
- សាររបស់ប្រព័ន្ធ
- ព័ត៌មានទូទៅ ។

**៧. ម៉ូឌុល CSS Database**

ម៉ូឌុល Database ផ្តល់លទ្ធភាពធ្វើការទាញយក និងធ្វើបច្ចុប្បន្នកម្មលើទិន្នន័យមូលដ្ឋានដោយមិនប្រកាន់ប្រភេទនៃទិន្នន័យមូលដ្ឋាន និងអ្នកប្រើប្រាស់ពុំចាំបាច់មានចំណេះដឹងស៊ីជម្រៅលើទិន្នន័យមូលដ្ឋាន ។

**៨. ការធ្វើបច្ចុប្បន្នកម្ម និងការថែទាំ**

សភាជាត់ទាត់ជាតិនឹងផ្តល់សេវាធ្វើបច្ចុប្បន្នកម្ម និងថែទាំប្រព័ន្ធ ដូចខាងក្រោម ៖

- បន្ថែម ឬលុបឈ្មោះសមាជិក ឬព័ត៌មានរបស់សមាជិក
- ធ្វើបច្ចុប្បន្នកម្មលើប្រព័ន្ធ CSS និងសម្ភារៈប្រព័ន្ធរបស់សភាជាត់ទាត់ជាតិតាមការចាំបាច់ ។

**ឧបសម្ព័ន្ធ៨ - អាសយដ្ឋានសម្រាប់ទំនាក់ទំនងជាមួយសភាផាត់ទាត់ជាតិ**

រាល់ព័ត៌មានពាក់ព័ន្ធនឹងសភាផាត់ទាត់ជាតិ ដូចជា ការស្នើសុំចូលជាសមាជិក ការជូនដំណឹង និងការស្នើសុំព័ត៌មានផ្សេងៗ សមាជិកអាចទាក់ទងផ្ទាល់មកសភាផាត់ទាត់ជាតិ ឬតាមរយៈការធ្វើលិខិតជាលាយលក្ខណ៍អក្សរដែលត្រូវផ្ញើជូន ៖

**១- អាសយដ្ឋាន**

អគ្គនាយកបច្ចេកទេស
ធនាគារជាតិនៃកម្ពុជា
២២-២៤ មហាវិថីព្រះនរោត្តម
ភ្នំពេញព្រះរាជាណាចក្រកម្ពុជា

**២- សារអេឡិចត្រូនិក**

ច្បាប់ចម្លងជាអេឡិចត្រូនិកអាចផ្ញើទៅ ៖
អ៊ីម៉ែល: nch@nbc.org.kh
សភាផាត់ទាត់ជាតិ
ធនាគារជាតិនៃកម្ពុជា

**៣- លេខទូរស័ព្ទទំនាក់ទំនង**

លេខទូរស័ព្ទទំនាក់ទំនងរបស់ការិយាល័យសភាផាត់ទាត់ធនាគារជាតិនៃកម្ពុជា
០២៣ ៧២២ ៥៦៣ ។

**លេខទូរស័ព្ទទំនាក់ទំនងផ្ទាល់**

០១៦ ៧០ ៤៤ ១១
០១២ ៧៦ ៧៥ ១១
០៩៧ ៧៧៧ ៨៣ ១១

## ឧបសម្ព័ន្ធ៩ - ប្រព្រឹត្តិកម្មលើប្រតិបត្តិការនៃប្រព័ន្ធ CSS

**១- ប្រព្រឹត្តិកម្មនៃការទទួលយកការទូទាត់តាមរយៈ ATM**

**១.១- កម្រិតកំណត់ចំនួនប្រាក់នៃប្រតិបត្តិការ ATM**

ACQ អាចកំណត់កម្រិតអតិបរមាចំនួនប្រាក់ត្រូវដកក្នុងមួយប្រតិបត្តិការចំពោះអ្នកកាន់ប័ណ្ណ ។ ការកំណត់នេះមិនត្រូវលើសពី ៤លានរៀល ឬសមមូលក្នុងមួយប្រតិបត្តិការ ។

**១.២- ការទទួលយកការទូទាត់របស់ ACQ**

ACQ ត្រូវអនុញ្ញាតឲ្យអ្នកកាន់ប័ណ្ណដែលចេញផ្សាយដោយសមាជិកដទៃ អាចធ្វើប្រតិបត្តិការដោយផ្ទាល់លើរាល់ ATM របស់ខ្លួន ។ ក្រោយពីបានទទួលសារ "**ការទទួលយកការទូទាត់**" ពី ISS តាមរយៈប្រព័ន្ធ CSS ACQ ត្រូវបញ្ចប់ប្រតិបត្តិការទូទាត់ និងផ្តល់របាយការណ៍សង្ខេបនូវព័ត៌មាននៃប្រតិបត្តិការនោះជូនអ្នកកាន់ប័ណ្ណ ។

**១.៣- ការទទួលយកការទូទាត់របស់ ISS**

ISS ត្រូវផ្ទៀងផ្ទាត់សារ "**សំណើទូទាត់**" ដែលទទួលបានពី ACQ តាមរយៈប្រព័ន្ធ CSS ស្របតាមនីតិវិធីដែលបានកំណត់ ។ ក្នុងករណីដែលការទូទាត់អាចប្រព្រឹត្តិទៅបាន ISS ត្រូវបញ្ជូនសារ "**ការទទួលយកការទូទាត់**" ទៅ ACQ វិញតាមរយៈប្រព័ន្ធ CSS ។

**១.៤- ការបដិសេធការទូទាត់**

**១.៤.១- ការបដិសេធការទូទាត់ដោយ ACQ**

ACQ អាចបដិសេធមិនទូទាត់ និងជូនដំណឹងអំពីមូលហេតុនៃការបដិសេធទៅអ្នកកាន់ប័ណ្ណ តាមនីតិវិធីនៃការជូនដំណឹងរបស់ ACQ ក្នុងករណីដូចខាងក្រោម ៖

ក. នៅពេលអ្នកកាន់ប័ណ្ណធ្វើប្រតិបត្តិការតាម ATM ដែលមិនបានកំណត់ដោយ ACQ ។

ខ. នៅពេល ACQ ផ្ទៀងផ្ទាត់ឃើញថា ប្រតិបត្តិការដែលអ្នកកាន់ប័ណ្ណធ្វើឡើងមិនស្របតាមខ្លឹមសារនៃវិធាននិងនីតិវិធី ។

គ. នៅពេល ACQ ទទួលបានសារ "**ការបដិសេធការទូទាត់**" ពី ISS ដែលអនុលោមតាមវិធាននិងនីតិវិធី ។

ឃ. នៅពេល ACQ ទទួលបានការឆ្លើយតបពីប្រព័ន្ធ CSS អំពីកំហុសឆ្គងនៃប្រតិបត្តិការ ។

ង. នៅពេលប្រតិបត្តិការមិនបានបញ្ចប់ ឬ ACQ មិនអាចបញ្ជាក់អំពីការបញ្ចប់នៃប្រតិបត្តិការដោយសារភាពរអាក់រអួលនៃប្រព័ន្ធរបស់ ACQ ISS ឬប្រព័ន្ធ CSS ។

ច. នៅពេល ATM មិនអាចដំណើរការបាន ដោយសារភាពរអាក់រអួល ដូចមានចែងក្នុងករណី "**ង**" ។

ក្នុងករណី ISS បដិសេធការទូទាត់តាម ATM ACQ មិនត្រូវទូទាត់ឱ្យទៅអ្នកកាន់ប័ណ្ណទេ ហើយ ត្រូវជូនដំណឹងទៅអ្នកកាន់ប័ណ្ណឱ្យធ្វើការទំនាក់ទំនងជាមួយ ISS ដោយផ្ទាល់ ។ ក៏ប៉ុន្តែប្រសិនបើ ACQ ទទួលសារអេឡិចត្រូនិចពី ISS ទទួលស្គាល់ "**ការទទួលយកការទូទាត់**" នោះ ACQ មិនត្រូវបដិសេធលើការទូទាត់ទៅឲ្យអ្នកកាន់ប័ណ្ណឡើយ ។

នៅពេលដែល ACQ បដិសេធការទូទាត់តាម ATM ពីអ្នកកាន់ប័ណ្ណ ACQ ត្រូវចេញរបាយការណ៍ប្រតិបត្តិការបញ្ជាក់ពីមូលហេតុ ទៅកាន់អ្នកកាន់ប័ណ្ណវិញ ។ ប៉ុន្តែ នៅពេល ACQ មិនអាចបញ្ជាក់ពីមូលហេតុនៃការបដិសេធការទូទាត់ នោះ ACQ ត្រូវណែនាំអ្នកកាន់ប័ណ្ណឱ្យទាក់ទងផ្ទាល់ជាមួយ ISS ។

**១.៤.២- ការបដិសេធការទូទាត់ដោយ ISS**

នៅពេល ISS ពិនិត្យសារ "**សំណើទូទាត់**" ពី ACQ តាមរយៈប្រព័ន្ធ CSS ហើយផ្ទៀងផ្ទាត់ឃើញថា សំណើនេះមិនស្របតាមវិធាននិងនិតិវិធីសម្រាប់ការទទួលយកការទូទាត់របស់ ISS នោះ ISS ត្រូវជូនដំណឹងជាសារ "**ការបដិសេធការទូទាត់**" ទៅកាន់ ACQ តាមរយៈប្រព័ន្ធ CSS ដោយភ្ជាប់ជាមួយនូវមូលហេតុពីការបដិសេធដែលបានកំណត់ដោយប្រព័ន្ធ CSS ។

**១.៤.៣- កិច្ចដំណើរការចែករំលែកព័ត៌មានអំពីប្រតិបត្តិការសង្ស័យ**

សមាជិកត្រូវចែករំលែកព័ត៌មានប្រតិបត្តិការសង្ស័យ ដូចខាងក្រោម ៖

**ក. ការចែករំលែកព័ត៌មានសង្ស័យ** ៖ នៅពេលសមាជិក ពិនិត្យឃើញថា ប្រតិបត្តិការផ្ទេរប្រាក់ណាមួយអាចជាការក្លែងបន្លំ ហើយកំណត់ថាជាប្រតិបត្តិការសង្ស័យ ISS ត្រូវបញ្ចូលព័ត៌មាននោះទៅក្នុងសារដែលត្រូវបញ្ជូនចេញ ។ សមាជិកមានកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសង្ស័យទៅអាជ្ញាធរពាក់ព័ន្ធ ។

**ខ. ការចែករំលែកព័ត៌មានអំពីការផ្អាកការដកប្រាក់ជាបណ្ដោះអាសន្ន** ៖ នៅពេលសមាជិកធ្វើការផ្អាកការដកប្រាក់ជាបណ្ដោះអាសន្នដោយមូលហេតុសមាជិករកឃើញថាគណនីរបស់អ្នកកាន់ប័ណ្ណ ជាគណនីសង្ស័យដែលអាចបង្កការខាតបង់ដល់អ្នកដទៃដោយការបន្លំ សមាជិកនោះត្រូវបញ្ជូនសារព័ត៌មានទៅកាន់សមាជិកពាក់ព័ន្ធភ្លាមៗ ។

**១.៥- ប្រព្រឹត្តិកម្មលើភាពរអាក់រអួល**

**១.៥.១- គោលការណ៍នៃប្រព្រឹត្តិកម្មលើភាពរអាក់រអួល**

ភាពរអាក់រអួល (Disorder) សំដៅលើស្ថានភាពរបស់ប្រព័ន្ធ CSS ប្រព័ន្ធរបស់សមាជិក និង/ឬ ATM មួយចំនួនឬទាំងអស់របស់ ACQ មិនអាចដំណើរការដូចធម្មតាដែលជាហេតុធ្វើឲ្យប្រតិបត្តិការអនឡាញមិនអាចប្រព្រឹត្តទៅបាន ។

ជាគោលការណ៍ នៅពេលភាពរអាក់រអួលកើតមានឡើង សមាជិកមិនត្រូវដោះស្រាយប្រតិបត្តិការតាមរយៈ ATM ឡើយ ។ ភាពរអាក់រអួលដែលកើតឡើងនៅ ACQ នោះសមាជិកត្រូវដោះស្រាយប្រតិបត្តិការដោយយោងតាមលទ្ធផលប្រព្រឹត្តិកម្មរបស់សភាផាត់ទាត់ជាតិ ។

**១.៥.២- សេចក្តីណែនាំដល់អ្នកកាន់ប័ណ្ណពីភាពរអាក់រអួល**

នៅពេលភាពរអាក់រអួលកើតមានឡើងចំពោះ ACQ នោះត្រូវណែនាំអ្នកកាន់ប័ណ្ណធ្វើប្រតិបត្តិការនៅ ATM របស់សមាជិកដទៃទៀត ។

នៅពេលភាពរអាក់រអួលកើតមានឡើងចំពោះប្រព័ន្ធ CSS ឬ ISS ណាមួយ ACQ ត្រូវណែនាំអ្នកកាន់ប័ណ្ណធ្វើប្រតិបត្តិការដោយផ្ទាល់ជាមួយ ISS ។

**១.៥.៣- ការទទួលខុសត្រូវលើការស្រោចស្រង់ភាពរអាក់រអួល**

នៅពេលមានភាពរអាក់រអួលកើតឡើងក្នុងប្រព័ន្ធ CSS ប្រព័ន្ធសមាជិក ឬបណ្តាញទំនាក់ទំនងភាគីពាក់ព័ន្ធត្រូវទទួលខុសត្រូវលើដំណើរការស្រោចស្រង់ភាពរអាក់រអួល ។

**១.៥.៤- សេចក្តីជូនដំណឹងអំពីការកើតមានភាពរអាក់រអួល**

នៅពេលកើតមានភាពរអាក់រអួលសមាជិកត្រូវជូនដំណឹងដល់សភាផាត់ទាត់ជាតិជាបន្ទាន់អំពីព័ត៌មានលម្អិត និងមូលហេតុនៃភាពរអាក់រអួល ពេលវេលាស្រោចស្រង់ដែលរំពឹងទុក បន្ទាប់មកអនុវត្តតាមនីតិវិធីនៃលក្ខណៈបច្ចេកទេសរបស់ប្រព័ន្ធ និងចាត់វិធានការពាក់ព័ន្ធដើម្បីស្រោចស្រង់ ។

សភាផាត់ទាត់ជាតិត្រូវជូនព័ត៌មាននៃភាពរអាក់រអួលទៅឱ្យសមាជិកដទៃ បន្ទាប់ពីមានសំណូមពរពីសមាជិកដែលស្ថិតក្នុងភាពរអាក់រអួលតាមរយៈអ៊ីម៉ែល ។

សភាផាត់ទាត់ជាតិនឹងជូនព័ត៌មានអំពីភាពរអាក់រអួលដល់សមាជិកទាំងអស់ នៅពេលមានភាពរអាក់រអួលក្នុងប្រព័ន្ធ CSS ។

**១.៥.៥- សេចក្តីជូនដំណឹងអំពីការស្រោចស្រង់ភាពរអាក់រអួល**

សមាជិកត្រូវជូនដំណឹងដល់សភាផាត់ទាត់ជាតិអំពីការស្រោចស្រង់នៅពេលភាពរអាក់រអួលវិលត្រឡប់មកសភាពដើមវិញ ។

សភាផាត់ទាត់ជាតិត្រូវជូនព័ត៌មានអំពីវឌ្ឍនភាព និងការបញ្ចប់ការស្រោចស្រង់ទៅសមាជិកដទៃប្រសិនបើសមាជិកនោះស្នើសុំឱ្យជូនព័ត៌មានតាមរយៈអ៊ីម៉ែល ។

នៅពេលភាពរអាក់រអួលក្នុងប្រព័ន្ធ CSS បានវិលត្រឡប់មកសភាពដើមវិញទាំងស្រុង សភាផាត់ទាត់ជាតិត្រូវជូនព័ត៌មានអំពីការស្រោចស្រង់នេះដល់សមាជិកទាំងអស់ ។

**១.៥.៦- ប្រព្រឹត្តិកម្មប្រតិបត្តិការមានសុពលភាពផ្នែក ACQ**

ប្រតិបត្តិការមានសុពលភាពផ្នែក ACQ គឺជាប្រតិបត្តិការដែល ACQ មិនបានបញ្ចប់ដោយសារភាពរអាក់រអួលនៃ ATM របស់ ACQ ឬភាពរអាក់រអួលនៃប្រព័ន្ធរបស់ ACQ ទោះជា ACQ ដឹងពីលទ្ធផលនៃប្រព្រឹត្តិកម្មក៏ដោយ ។

ជាគោលការណ៍នៅពេល **"ប្រតិបត្តិការមានសុពលភាពផ្នែក ACQ"** កើតមានឡើង ACQ មិនត្រូវស្នើសុំលទ្ធផលប្រព្រឹត្តិកម្មពីប្រព័ន្ធ CSS ឬ ISS ឡើយ ។ ACQ ត្រូវបញ្ជាក់លទ្ធផលប្រព្រឹត្តិកម្មរបស់ខ្លួនដោយមធ្យោបាយនានា ។

នៅពេលលទ្ធផលប្រព្រឹត្តិកម្មគឺជា "**ការទទួលយកការទូទាត់**" ACQ ត្រូវទូទាត់ជូនទៅអ្នកកាន់ប័ណ្ណ និងបោះពុម្ពឯកសារដែលអះអាងពីការទូទាត់ ។ ក្នុងករណីនេះ ACQ ត្រូវមានការប្រុងប្រយ័ត្នដោយមិនឱ្យប្រព្រឹត្តិកម្មនៃប្រតិបត្តិការកើតមានស្ទួនគ្នា ពីព្រោះ ACQ អាចនឹងទូទាត់ឱ្យអ្នកកាន់ប័ណ្ណ និងផ្ញើសារ "**Reverse ការទូទាត់**" ទៅ ISS ព្រមគ្នា ។

ក្នុងករណីលទ្ធផលប្រព្រឹត្តិកម្មគឺជា "**ការបដិសេធការទូទាត់**" ACQ ត្រូវប្រគល់ប័ណ្ណទៅអ្នកកាន់ប័ណ្ណវិញនិងជូនដំណឹងអំពីមូលហេតុនៃការបដិសេធការទូទាត់ដល់អ្នកកាន់ប័ណ្ណ ។

នៅពេល ACQ មិនអាចបញ្ជាក់ពីលទ្ធផលប្រព្រឹត្តិកម្ម ACQ ត្រូវបង្អាកទុកការទូទាត់រហូតដល់ពេលអាចបញ្ជាក់អំពីលទ្ធផលបាន ។

លទ្ធផលប្រព្រឹត្តិកម្មនៃប្រតិបត្តិការដែលជា "**ការទទួលយកការទូទាត់**" ត្រូវបានបញ្ចូលជាប្រតិបត្តិការក្នុងថ្ងៃ និងត្រូវបានទូទាត់ ។

**១.៥.៧- ប្រព្រឹត្តិកម្មពិសេសនៃប្រតិបត្តិការមានសុពលភាពផ្នែក ACQ**

ក្នុងចំណោម "**ប្រតិបត្តិការមានសុពលភាពផ្នែក ACQ**" ប្រតិបត្តិការណាដែលបានបញ្ជាក់ថាជា "**ការទទួលយកការទូទាត់**" មិនត្រូវបានទូទាត់ដោយសារអ្នកកាន់ប័ណ្ណចាកចេញពី ATM ACQ ត្រូវ Reverse ប្រតិបត្តិការ យោងតាមប្រព្រឹត្តិកម្មនៃការ Reverse ការទូទាត់ ។

នៅពេលអ្នកកាន់ប័ណ្ណចាកចេញ ដោយប័ណ្ណរបស់ខ្លួននៅជាប់ក្នុង ATM ដោយសារភាពរអាក់រអួលនៃ ATM ឬប្រព័ន្ធរបស់ ACQ នោះ ACQ ត្រូវពិភាក្សាជាមួយនឹង ISS ដើម្បីកំណត់ពីមធ្យោបាយប្រព្រឹត្តិកម្ម ។

**១.៦- ប្រព្រឹត្តិកម្មនៃប័ណ្ណដែលត្រូវបានលេប**

សមាជិកត្រូវធានាថាប្រព័ន្ធរបស់ខ្លួនមិនលេបប័ណ្ណក្នុងករណីវាយបញ្ចូលលេខសម្ងាត់មិនត្រឹមត្រូវ ។

ក្នុងករណីប័ណ្ណត្រូវបានលេប ACQ ត្រូវណែនាំអ្នកកាន់ប័ណ្ណឱ្យទាក់ទងទៅកាន់ ISS នៅពេលដែលអតិថិជនទាក់ទងទៅកាន់ ACQ ។ ក្នុងរយៈពេល ១០ ថ្ងៃគិតចាប់ពីថ្ងៃដែលប័ណ្ណត្រូវបានលេប នោះ ACQ នឹងផ្តល់ការសម្រេចចិត្តមួយ ថាតើត្រូវទុកផ្ញើ ឬបង្វិលត្រឡប់វិញនូវប័ណ្ណ ដោយផ្អែកលើសំណើពី ISS ។ បើលើសពី១០ថ្ងៃនៃថ្ងៃធ្វើការ នៅតែគ្មានសំណើពី ISS/ACQ នឹងបំផ្លាញប័ណ្ណដោយចោះនៅផ្នែក Magnetic Tape នៃប័ណ្ណ ហើយ ACQ នឹងបូកសរុបជាប្រចាំខែនូវចំនួនប័ណ្ណដែលបានបំផ្លាញដើម្បីផ្ញើទៅ ISS ។

**១.៧- ប្រព្រឹត្តិកម្មនៃ Reverse ការទូទាត់**

Reversal (ការចុះបញ្ច្រាសការទូទាត់) សំដៅលើស្ថានភាពដែល ISS បានធ្វើប្រតិបត្តិការដោយផ្អែកទៅលើសារស្នើសុំទូទាត់របស់ ACQ ប៉ុន្តែប្រតិបត្តិការមិនទាន់បញ្ចប់ដោយសារភាពរអាក់រអួលពី ATM របស់ ACQ ពីប្រព័ន្ធរបស់ ACQ ឬប្រព័ន្ធ CSS ដូច្នេះ ISS ត្រូវចុះបញ្ច្រាស់ប្រតិបត្តិការមកវិញ ទៅតាមសំណើរបស់ ACQ ឬប្រព័ន្ធ CSS ។

**១.៧.១- Reverse ការទូទាត់ដោយ ISS**

នៅពេល ISS បានដំណើរការប្រតិបត្តិការមួយដោយយោងតាមសារ "**សំណើទូទាត់**" របស់ ACQ ប៉ុន្តែប្រតិបត្តិការនោះមិនបានបញ្ចប់ដោយសារភាពរអាក់រអួលនៃ ATM របស់ ACQ ប្រព័ន្ធរបស់ ACQ ឬប្រព័ន្ធ CSS ក្នុងករណីនេះ ISS ត្រូវ Reverse ប្រតិបត្តិការ តាមសំណើរបស់ ACQ ឬប្រព័ន្ធ CSS ។

Rerverse ការទូទាត់ ត្រូវធ្វើឡើងក្នុងថ្ងៃទូទាត់ដដែល (មុន Cut-off Time របស់ប្រព័ន្ធ CSS) ពោលគឺប្រតិបត្តិការមិនអាច Rerverse ក្រោយ Cut-off Time ឡើយ ។

**១.៧.២- Rerverse ការទូទាត់ដោយ ACQ**

នៅពេល ACQ មិនអាចធ្វើការទូទាត់បាន ដោយសារភាពរអាក់រអួលនៃ ATM របស់ ACQ ប្រព័ន្ធរបស់ ACQ ឬបណ្តាញរវាង ATM និង ACQ ទោះជាក្រោយពេលទទួលបានសារ "**ការទទួលយកការទូទាត់**" ពីប្រព័ន្ធ CSS ក៏ដោយ ACQ ត្រូវផ្ញើសារ "**សំណើ Rerverse ការទូទាត់**" ទៅកាន់ប្រព័ន្ធ CSS វិញ ។ ក្នុងករណីដែល ACQ បញ្ជូនសារ "**សំណើ Rerverse ការទូទាត់**" ISS ត្រូវធ្វើប្រតិបត្តិការ Rerverse នេះ ។

នៅពេលទទួលបានសារ "**ការទទួលយកការទូទាត់**" ប៉ុន្តែ ACQ មិនអាចផ្ញើសារ "**សំណើ Rerverse ការទូទាត់**" ទៅកាន់ប្រព័ន្ធ CSS បានដោយសារមូលហេតុរបស់ ACQ នោះ ACQ ត្រូវទូទាត់ជូនអ្នកកាន់ប័ណ្ណ ។ ក្នុងករណីនេះ ប្រតិបត្តិការត្រូវបានចាត់ទុកថាជាប្រតិបត្តិការប្រក្រតី ។

**១.៧.៣- Reverse ការទូទាត់ដោយប្រព័ន្ធ CSS**

នៅពេលប្រព័ន្ធ CSS ទទួលបានសារ "**សំណើ Reverse ការទូទាត់**" ពី ACQ ប្រព័ន្ធ CSS ត្រូវផ្ញើសារ "**ការទទួលបានសំណើ Reverse ការទូទាត់**" ទៅកាន់ ACQ និងផ្ញើសារ "**បញ្ជា Reverse ការទូទាត់**" ទៅកាន់ ISS ។ ប្រព័ន្ធ CSS នឹងធ្វើ Reverse ប្រតិបត្តិការដែលពាក់ព័ន្ធ ។

នៅពេលប្រព័ន្ធ CSS មិនបានទទួលសារ "**ការទទួលយកការទូទាត់**" ពី ISS ប្រព័ន្ធ CSS នឹងធ្វើ Reverse ប្រតិបត្តិការដែលពាក់ព័ន្ធ ។

នៅពេលប្រព័ន្ធ CSS មិនអាចផ្ញើសារ "**ការទទួលយកការទូទាត់**" ទៅកាន់ ACQ ដោយសារភាពរអាក់រអួលរបស់ ACQ ឬបណ្តាញ ដូច្នេះ ACQ ត្រូវផ្ញើសារ "**សំណើ Reverse ការទូទាត់**" ទៅកាន់ប្រព័ន្ធ CSS ។

**១.៨- ប្រព្រឹត្តិកម្មលើប្រតិបត្តិការបរាជ័យ**

ប្រតិបត្តិការបរាជ័យ **(Fail Transaction)** សំដៅលើប្រតិបត្តិការដែលប្រព័ន្ធ CSS ឬ ACQ ពុំទាន់បានបញ្ចប់គ្រប់ដំណាក់កាល ។

**១.៨.១- ប្រភេទនៃប្រតិបត្តិការបរាជ័យ**

ប្រតិបត្តិការបរាជ័យនៃ ACQ គឺជាប្រតិបត្តិការណាដែលសារ "**សំណើ Reverse ការទូទាត់**" មិនអាចផ្ញើទៅកាន់ប្រព័ន្ធ CSS បាន ។

ប្រភេទនៃប្រតិបត្តិការបរាជ័យនៃប្រព័ន្ធ CSS មានដូចខាងក្រោម ៖

ក. ប្រតិបត្តិការណាដែលសារ "**បញ្ជា Reverse ការទូទាត់**" មិនអាចផ្ញើទៅកាន់ ISS ក្រោយពីទទួលបានសារ "**សំណើ Reverse ការទូទាត់**" ពី ACQ

ខ. ប្រតិបត្តិការបរាជ័យចេញពី ISS ដោយមានមូលហេតុមួយចំនួន ៖ មូលនិធិមិនគ្រប់គ្រាន់ គណនីអសកម្ម និងប្រព័ន្ធកំពុងត្រូវបានថែទាំជាដើម

គ. ប្រតិបត្តិការ Reverse

ឃ. ប្រតិបត្តិការណាដែល ISS មិនបានផ្ញើសារ "**ការទទួលយកការទូទាត់**" ដោយសារហួសពេលកំណត់ (Time Out)

ង. ប្រតិបត្តិការណាដែលប្រព័ន្ធ CSS បានផ្ញើសារ "**ការទទួលយកការទូទាត់**" ទៅកាន់ ACQ ប៉ុន្តែ ACQ មិនបានទទួលសារ ដោយសារហួសពេលកំណត់ ។

**១.៨.២- ប្រព្រឹត្តិកម្មរបស់ប្រព័ន្ធ CSS លើប្រតិបត្តិការបរាជ័យ**

ប្រព័ន្ធ CSS ត្រូវផ្ញើសារ "**កំណត់សម្គាល់នៃប្រតិបត្តិការបរាជ័យ**" ទៅកាន់សមាជិកពាក់ព័ន្ធ ។ នៅពេលមានការស្នើសុំ Reverse ប្រតិបត្តិការក្នុងចំណោមប្រតិបត្តិការបរាជ័យ នោះប្រព័ន្ធ CSS ត្រូវផ្ញើសារ "**ការបញ្ចប់នៃសំណើ Reverse ប្រតិបត្តិការ**" ។

**១.៨.៣- ប្រព្រឹត្តិកម្មរបស់ ISS លើប្រតិបត្តិការបរាជ័យ**

ISS ត្រូវពិនិត្យភ្លាមៗនូវលទ្ធផលប្រព្រឹត្តិកម្មនៃប្រតិបត្តិការក្រោយពីទទួលបានសំណើ Reverse ប្រតិបត្តិការពីប្រព័ន្ធ CSS ។

ISS ត្រូវធ្វើការ Reverse ប្រតិបត្តិការក្នុងប្រព័ន្ធរបស់ខ្លួនភ្លាមៗ និងឆ្លើយតបទៅកាន់ប្រព័ន្ធ CSS អំពីការបញ្ចប់ការ Reverse ប្រតិបត្តិការនេះនូវចំនួនទឹកប្រាក់ពេញលេញ រួមទាំងកម្រៃទៅក្នុងគណនីរបស់អ្នកកាន់ប័ណ្ណ ។

**១.៨.៤- ការមិនទូទាត់ប្រតិបត្តិការបរាជ័យ**

ប្រព័ន្ធ CSS នឹងមិនបញ្ចូលប្រតិបត្តិការបរាជ័យទៅក្នុងការទូទាត់ឡើយ ។

**១.៩- ប្រព្រឹត្តិកម្មនៃលទ្ធផលប្រតិបត្តិការ**

នៅពេលអ្នកកាន់ប័ណ្ណត្រូវការបញ្ជាក់អំពីលទ្ធផលនៃប្រតិបត្តិការប័ណ្ណ ACQ ត្រូវឆ្លើយតបទៅកាន់អ្នកកាន់ប័ណ្ណវិញនូវលទ្ធផល ដោយភ្ជាប់ជាមួយនឹងសារបញ្ជាក់ដែលរួមមានលេខសម្គាល់ប្រតិបត្តិការ ចំនួនប្រាក់ កាលបរិច្ឆេទ និងលទ្ធផលនៃប្រតិបត្តិការដែលបានបង្ហាញលើវិក្កយបត្រ ។

**១.១០- ការទទួលខុសត្រូវលើការខាតបង់**

- នៅពេលមានការខាតបង់ដោយសារ ACQ ល្មើសនឹងវិធាននិងនីតិវិធី ឬនៅពេលមានការខាតបង់ដោយសារភាពរអាក់រអួលនៃប្រព័ន្ធរបស់ ACQ ឬមូលហេតុផ្សេងៗដែលជាបន្ទុករបស់ ACQ នោះ ACQ ត្រូវទទួលខុសត្រូវលើការបាត់បង់នេះជាចំណាយរបស់ ACQ ។

- នៅពេលមានការខាតបង់ដោយសារ ISS ល្មើសនឹងវិធាននិងនីតិវិធី ឬនៅពេលមានការខាតបង់ដោយសារភាពរអាក់រអួលនៃប្រព័ន្ធរបស់ ISS ឬមូលហេតុផ្សេងៗដែលជាបន្ទុករបស់ ISS នោះ ISS ត្រូវទទួលខុសត្រូវលើចំណាយការខាតបង់នេះ ។
- នៅពេលមានការខាតបង់ដោយសារ ISS និង ACQ ល្មើសនឹងវិធាននិងនីតិវិធី ឬនៅពេលមានការខាតបង់ដោយសារភាពរអាក់រអួលនៃប្រព័ន្ធរបស់ ISS និង ACQ ឬមូលហេតុផ្សេងៗដែលជាបន្ទុកលើពួកគេ ។ ក្នុងករណីនេះ ISS និង ACQ ត្រូវទទួលខុសត្រូវលើការចំណាយការខាតបង់របស់ពួកគេ ដោយផ្អែកលើទំហំនៃការខាតបង់ ។
- នៅពេលមិនអាចវែកញែកថា ការខាតបង់ជាបន្ទុករបស់សមាជិកណាមួយ នោះ ISS និង ACQ ត្រូវសហការគ្នាដោះស្រាយការខាតបង់នេះ ។

**១.១១- Liability Shift**

ប្រសិនបើមានប្រតិបត្តិការក្លែងបន្លំកើតឡើង ការទទួលខុសត្រូវ (Liability) ធ្លាក់លើ ៖

- ISS ក្នុងករណីប័ណ្ណដែល Support តែ Magnetic Stripe ត្រូវបានប្រើប្រាស់លើម៉ាស៊ីនដែល Support តែ Magnetic stripe
- ISS ក្នុងករណីប័ណ្ណដែល Support តែ Magnetic Stripe ត្រូវបានប្រើប្រាស់លើម៉ាស៊ីនដែល Support តែ Chip
- ACQ ក្នុងករណីប័ណ្ណដែល Support Chip ត្រូវបានប្រើប្រាស់លើម៉ាស៊ីនដែល Support Magnetic Stripe
- ISS ក្នុងករណីប័ណ្ណដែល Support Chip ត្រូវបានប្រើប្រាស់លើម៉ាស៊ីនដែល Support Chip

**១.១២- ប្រព្រឹត្តិកម្មសមាជិកក្នុងគ្រាអាសន្ន**

សមាជិកដែលស្ថិតក្នុងស្ថានភាពអាសន្នត្រូវស្នើសុំការសម្រេចពីសភាផាត់ទាត់ជាតិដើម្បីទទួលស្គាល់ ។

នៅពេលសភាផាត់ទាត់ជាតិទទួលបានព័ត៌មានអំពីស្ថានភាពអាសន្នពីសមាជិកណាមួយ ឬសភាផាត់ទាត់ជាតិទទួលស្គាល់ថាជារឿងជាក់ស្តែងទោះបីជាសមាជិកមិនបានស្នើសុំការសម្រេច ក៏សភាផាត់ទាត់ជាតិចាត់ទុកថាសមាជិកនោះស្ថិតក្នុងស្ថានភាពអាសន្នដែរ ។

ស្ថានភាពអាសន្នរួមមាន ៖

- ករណីប្រធានសក្តិ
- ដាច់ចរន្តអគ្គិសនី
- ដាច់បណ្តាញទំនាក់ទំនង
- បញ្ហាគ្រោះអាសន្នផ្សេងទៀតដែលរារាំងដល់កិច្ចដំណើរការនិងប្រតិបត្តិការប្រព័ន្ធ ។

**២- ប្រព្រឹត្តិកម្មនៃប្រតិបត្តិការ POS**

**២.១- កម្រិតកំណត់ចំនួនប្រាក់នៃប្រតិបត្តិការ POS**

ACQ និង Merchants របស់ខ្លួនមិនត្រូវកំណត់កម្រិតអប្បបរមាចំនួនប្រាក់ត្រូវទិញ ឬបង់ក្នុងមួយប្រតិបត្តិការចំពោះអ្នកកាន់ប័ណ្ណឡើយ ។

**២.២- ប្រព្រឹត្តិកម្មកិច្ចដំណើរការប័ណ្ណទូទាត់**

នៅពេលព័ត៌មាននៃប្រតិបត្តិការប័ណ្ណទូទាត់ដូចជាចំនួនប្រាក់និងសារអនុញ្ញាតត្រូវបានបញ្ជូនទៅប្រព័ន្ធ CSS ហើយប្រព័ន្ធ CSS ត្រូវណែនាំ ISS ឱ្យចុះឥណពន្ធនូវចំនួនប្រាក់នៃប្រតិបត្តិការប័ណ្ណទូទាត់ ។ ក្រោយពិនិត្យឃើញថាព័ត៌មានត្រឹមត្រូវ ISS ត្រូវចុះឥណពន្ធនូវចំនួនប្រាក់ពីគណនីអ្នកកាន់ប័ណ្ណ និងផ្ញើលទ្ធផលឥណពន្ធទៅកាន់ប្រព័ន្ធ CSS ។

ប្រព័ន្ធ CSS ត្រូវផ្ញើលទ្ធផលឥណពន្ធទៅកាន់ POS របស់ Merchant ហើយ POS ត្រូវបោះពុម្ពវិក្កយបត្រដែលមានព័ត៌មានប្រតិបត្តិការ ។ ក្នុងករណីប្រតិបត្តិការបរាជ័យព័ត៌មាននឹងបង្ហាញលើ Screen ។

**២.៣- កម្រិតលក្ខខណ្ឌនៃប្រតិបត្តិការប័ណ្ណទូទាត់**

សមាជិកអាចបដិសេធការទូទាត់នៃប្រតិបត្តិការប័ណ្ណ ក្នុងករណីដូចខាងក្រោម ៖

ក. សមតុល្យមិនគ្រប់គ្រាន់

ខ. ការវាយបញ្ចូលលេខសម្ងាត់ (PIN) មិនត្រឹមត្រូវលើសចំនួនដងដែលបានកំណត់ដោយ ISS

គ. លើសកម្រិតកំណត់ចំនួនប្រាក់ឥណពន្ធ

ឃ. មូលហេតុផ្សេងៗដែលបដិសេធដោយសមាជិក ។

**២.៤- ប្រព្រឹត្តិកម្មនៃសំណើសុំបញ្ជូនមូលនិធិត្រឡប់វិញ**

ការបញ្ជូនមូលនិធិត្រឡប់វិញ (Refund) សំដៅលើដំណើរការក្នុងការបញ្ជូនមូលនិធិនៃប្រតិបត្តិការដើមទៅគណនីរបស់អ្នកកាន់ប័ណ្ណវិញ ។

**២.៤.១- ការសម្របសម្រួល**

សមាជិកដែលបានស្នើសុំបញ្ជូនមូលនិធិត្រឡប់វិញត្រូវសហការជាមួយអ្នកកាន់ប័ណ្ណ ឬសមាជិកពាក់ព័ន្ធផ្សេងទៀត ដោយអនុលោមតាមវិធាននិងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ។

**២.៤.២- ប្រភេទនៃប្រតិបត្តិការបញ្ជូនមូលនិធិត្រឡប់វិញ**

ISS អាចធ្វើការស្នើសុំបញ្ជូនមូលនិធិត្រឡប់វិញនៃប្រតិបត្តិការពី ACQ ហើយ ACQ ត្រូវបញ្ជូនមូលនិធិត្រឡប់មក ISS វិញ នូវប្រតិបត្តិការដូចខាងក្រោម ៖

ក. ក្នុងចំណោម "**ប្រតិបត្តិការមានសុពលភាពផ្នែក ACQ**" ចំពោះប្រតិបត្តិការដែលបានបញ្ជាក់ថាជា "**ការទទួលយកការទូទាត់**" ប៉ុន្តែអ្នកកាន់ប័ណ្ណ និង Merchant យល់ព្រមបញ្ជូនមូលនិធិត្រឡប់វិញ ។

ខ. ប្រតិបត្តិការមិនត្រឹមត្រូវ ឧទាហរណ៍ ការបញ្ចូលចំនួនប្រាក់មិនត្រឹមត្រូវ ដោយកំហុសរបស់ Merchant ។

គ. ការបញ្ជូនមូលនិធិត្រឡប់វិញនូវប្រាក់កក់របស់អ្នកកាន់ប័ណ្ណ ឧទាហរណ៍ ប្រាក់កក់សណ្ឋាគារ ។

ឃ. ប្រតិបត្តិការដែលធ្វើឡើងក្រោយពីមានការស្នើសុំបញ្ឈប់ពីអ្នកកាន់ប័ណ្ណ ក្នុងករណីដូចជាការក្លែងបន្លំ ។

ង. ប្រតិបត្តិការផ្សេងៗទៀត ដែលតម្រូវឱ្យមានការបញ្ជូនមូលនិធិត្រឡប់វិញ ។

**២.៤.៣- ការបញ្ជាក់អំពីប្រតិបត្តិការបញ្ជូនមូលនិធិត្រឡប់វិញ**

សមាជិកត្រូវបញ្ជាក់ពីប្រតិបត្តិការណាដែលត្រូវធ្វើការបញ្ជូនមូលនិធិត្រឡប់វិញ ក្រោយពីពិនិត្យលើរបាយការណ៍ប្រតិបត្តិការសរុបរបស់ប្រព័ន្ធ CSS និងរបាយការណ៍ប្រតិបត្តិការសរុបរបស់សមាជិក ។

**២.៤.៤- ប្រព្រឹត្តិកម្មនៃការបញ្ជូនមូលនិធិត្រឡប់វិញដោយ ACQ**

ACQ ត្រូវធ្វើសំណើបញ្ជូនមូលនិធិត្រឡប់វិញដែលរួមបញ្ចូលនូវព័ត៌មានលម្អិតនិងមូលហេតុនៃការបញ្ជូនមូលនិធិត្រឡប់វិញទៅកាន់ប្រព័ន្ធ CSS មិនឱ្យលើសពី ៣០ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃធ្វើប្រតិបត្តិការដើម ។

**២.៤.៥- ប្រព្រឹត្តិកម្មនៃការបញ្ជូនមូលនិធិត្រឡប់វិញដោយប្រព័ន្ធ CSS**

នៅពេល CSS ទទួលបានសំណើបញ្ជូនមូលនិធិត្រឡប់វិញពី ACQ ដែលរួមបញ្ចូលនូវព័ត៌មានលម្អិតនិងមូលហេតុនៃការបញ្ជូនមូលនិធិត្រឡប់វិញ ប្រព័ន្ធ CSS ត្រូវបញ្ជូនសំណើនេះបន្តទៅឱ្យ ISS ពាក់ព័ន្ធ ។

ប្រព័ន្ធ CSS ត្រូវបញ្ជាក់អំពីលទ្ធផលនៃប្រព្រឹត្តិកម្ម និងបញ្ជូនលទ្ធផលទៅឱ្យសមាជិកពាក់ព័ន្ធ ។

**២.៤.៦- ប្រព្រឹត្តិកម្មនៃការបញ្ជូនមូលនិធិត្រឡប់វិញដោយ ISS**

នៅពេលបានទទួលសំណើសុំបញ្ជូនមូលនិធិត្រឡប់វិញពីប្រព័ន្ធ CSS នោះ ISS ត្រូវចុះបញ្ចូលមូលនិធិនេះទៅគណនីរបស់អ្នកកាន់ប័ណ្ណ និងបញ្ជាក់អំពីលទ្ធផលទៅប្រព័ន្ធ CSS ។ ប្រព័ន្ធ CSS នឹងបញ្ជូនលទ្ធផលបន្តទៅ ACQ ។

ក្នុងករណី ISS យល់ឃើញថា ការបញ្ជូនមូលនិធិត្រឡប់មានភាពចាំបាច់ ដូចជាការលួចបន្លំ ISS ត្រូវជូនដំណឹងទៅឱ្យ ACQ អំពីសំណើសុំបញ្ជូនមូលនិធិត្រឡប់ ។

ក្នុងករណី ISS ធ្វើសំណើសុំទៅ ACQ ឱ្យបញ្ជូនមូលនិធិត្រឡប់វិញដោយហេតុផលថា ប្រតិបត្តិការមិនត្រឹមត្រូវ ISS ត្រូវទទួលបានការអនុញ្ញាតពីអ្នកកាន់ប័ណ្ណជាមុនសិន ។

**២.៤.៧- ការទូទាត់ប្រតិបត្តិការបញ្ជូនមូលនិធិត្រឡប់វិញ**

ចំនួនប្រាក់នៃប្រតិបត្តិការបញ្ជូនមូលនិធិត្រឡប់វិញ ត្រូវដាក់ចូលទៅក្នុងការទូទាត់នៃថ្ងៃប្រតិបត្តិការបច្ចុប្បន្នរបស់ប្រព័ន្ធ CSS ។

**២.៥- ប្រព្រឹត្តិកម្មចំពោះការបញ្ជាក់លទ្ធផលប្រតិបត្តិការ និងការពិនិត្យសមតុល្យ**

**២.៥.១- ការបញ្ជាក់អំពីលទ្ធផលនៃប្រតិបត្តិការប័ណ្ណ**

នៅពេលអ្នកកាន់ប័ណ្ណត្រូវការបញ្ជាក់លទ្ធផលនៃប្រតិបត្តិការប័ណ្ណពី Merchant ACQ ត្រូវផ្តល់ដំណឹងជូនអ្នកកាន់ប័ណ្ណនូវលទ្ធផលដែលរួមបញ្ចូលលេខសម្គាល់ ចំនួនប្រាក់ និងកាលបរិច្ឆេទនៃប្រតិបត្តិការដែលបង្ហាញលើវិក្កយបត្រ ។

**២.៥.២- ការពិនិត្យសមតុល្យគណនី**

ISS និង ACQ ត្រូវអនុញ្ញាតការពិនិត្យសមតុល្យ នៅពេលអ្នកកាន់ប័ណ្ណស្នើសុំពិនិត្យសមតុល្យគណនីសម្រាប់ប័ណ្ណទូទាត់ តាមរយៈ POS របស់ Merchant ។

នៅពេលសារពិនិត្យសមតុល្យត្រូវបានផ្ញើពី POS តាមរយៈ ACQ ទៅដល់ប្រព័ន្ធ CSS នោះប្រព័ន្ធ CSS ត្រូវណែនាំ ISS ផ្តល់ព័ត៌មានសមតុល្យ ។ ISS ត្រូវផ្ញើលទ្ធផលនៃព័ត៌មានសមតុល្យនេះទៅកាន់ប្រព័ន្ធ CSS ក្នុងករណីលេខគណនី និងលេខសម្ងាត់ត្រឹមត្រូវ ។

ប្រព័ន្ធ CSS ត្រូវបញ្ជូនលទ្ធផលនៃព័ត៌មានសមតុល្យទៅឱ្យ ACQ បន្ទាប់មក ACQ ត្រូវបង្ហាញលើ POS ។

**២.៦- ផ្សេងៗ**

**២.៦.១- សេចក្តីជូនដំណឹងអំពីការប្រើប្រាស់ប័ណ្ណទូទាត់**

ចំពោះការធ្វើប្រតិបត្តិការនីមួយៗ ISS ត្រូវកត់ត្រាវិធីទូទាត់សងប្រាក់ ឈ្មោះ Merchant កាលបរិច្ឆេទ និងចំនួនប្រាក់នៃប្រតិបត្តិការ ទៅក្នុងគណនីរបស់អ្នកកាន់ប័ណ្ណ ។ ISS ត្រូវជូនដំណឹងទៅអ្នកកាន់ប័ណ្ណដោយភ្ជាប់ជាមួយកំណត់ត្រានេះ ។

**២.៦.២- ការបោះពុម្ពវិក្កយបត្រប្រតិបត្តិការប័ណ្ណទូទាត់**

នៅពេលប្រតិបត្តិការមួយត្រូវបានបញ្ចប់ ACQ ត្រូវឱ្យ Merchant ចេញវិក្កយបត្រជូនអ្នកកាន់ប័ណ្ណ ដែលរួមមានព័ត៌មានដូចខាងក្រោម ៖

ក. **ទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិការ** ៖ កាលបរិច្ឆេទនិងម៉ោងប្រតិបត្តិការ ចំនួនប្រាក់ប្រភេទរូបិយប័ណ្ណ អាករលើតម្លៃបន្ថែម ចំនួនប្រាក់សរុប លេខសម្គាល់ប្រតិបត្តិការ ប្រភេទប្រតិបត្តិការ កាលបរិច្ឆេទនៃប្រតិបត្តិការដើម (ក្នុងករណី Reversal ឬ ការបញ្ជូនមូលនិធិត្រឡប់វិញ) និងឈ្មោះ ACQ ។

ខ. **ទិន្នន័យពាក់ព័ន្ធនឹងអ្នកកាន់ប័ណ្ណ** ៖ ឈ្មោះ ISS និងលេខប័ណ្ណ៤ ខ្ទង់ចុងក្រោយរបស់អ្នកកាន់ប័ណ្ណ ។

គ. **ទិន្នន័យពាក់ព័ន្ធនឹង Merchant** ៖ លេខសម្គាល់របស់ Merchant ឈ្មោះ Merchant ឈ្មោះអ្នកតំណាង អាសយដ្ឋាន និងលេខទូរស័ព្ទ ។

ប្រសិនបើប្រតិបត្តិការមួយមិនបានបញ្ចប់ Merchant ត្រូវបង្ហាញ និង/ឬពន្យល់អំពីមូលហេតុដល់អ្នកកាន់ប័ណ្ណ ហើយមិនចេញវិក្កយបត្រជូនអ្នកកាន់ប័ណ្ណ ។

**២.៦.៣- សេចក្តីបញ្ជាក់អំពីព័ត៌មានលម្អិតនៃប្រតិបត្តិការប័ណ្ណទូទាត់**

នៅពេលអ្នកកាន់ប័ណ្ណស្នើសុំ ISS នូវលេខសម្គាល់ប្រតិបត្តិការ ដោយមូលហេតុបាត់វិក្កយបត្រ ISS ត្រូវផ្តល់ព័ត៌មានដល់អ្នកកាន់ប័ណ្ណ ក្រោយពីពិនិត្យឃើញថាបុគ្គលនោះគឺជាអ្នកកាន់ប័ណ្ណពិតប្រាកដ ។

**២.៧- ប្រព្រឹត្តិកម្មលើភាពរអាក់រអួល**

**២.៧.១- គោលការណ៍ប្រព្រឹត្តិកម្មនៃភាពរអាក់រអួល**

នៅពេលមានភាពរអាក់រអួល សភាផាត់ទាត់ជាតិនិងសមាជិកត្រូវជូនដំណឹងដល់អ្នកកាន់ប័ណ្ណអំពីស្ថានភាពជាក់ស្តែង និងណែនាំពួកគេឱ្យប្រើប្រាស់ឧបករណ៍ផ្សេងទៀត រហូតដល់ភាពរអាក់រអួលត្រូវបានស្រោចស្រង់ ។ ប៉ុន្តែ នៅពេលការស្រោចស្រង់ភាពរអាក់រអួលត្រូវបានពន្យាររយៈពេលវែង សភាផាត់ទាត់ជាតិនិងសមាជិកត្រូវសហការគ្នា ដើម្បីកាត់បន្ថយការលំបាករបស់អ្នកកាន់ប័ណ្ណ ។

នៅពេលភាពរអាក់រអួលកើតឡើងលើ POS នោះ ACQ ដែលទទួលខុសត្រូវលើ POS ត្រូវចាត់វិធានការសមស្រប ។

**២.៧.២- សេចក្តីជូនដំណឹងអំពីការកើតមានភាពរអាក់រអួល**

នៅពេលមានភាពរអាក់រអួល សមាជិក ឬ ACQ ត្រូវជូនដំណឹងដល់សភាផាត់ទាត់ជាតិភ្លាមៗ អំពីព័ត៌មានលម្អិតដោយបញ្ជាក់ពីមូលហេតុនៃភាពរអាក់រអួល ពេលវេលាស្រោចស្រង់រំពឹងទុក និងបន្ទាប់មកត្រូវអនុលោមតាមនីតិវិធីបទដ្ឋានរបស់ប្រព័ន្ធដើម្បីចាត់វិធានការពាក់ព័ន្ធសម្រាប់ការស្រោចស្រង់ ។

នៅពេលប្រព័ន្ធ CSS មានភាពរអាក់រអួល សភាផាត់ទាត់ជាតិត្រូវជូនដំណឹងពីភាពរអាក់រអួលទៅកាន់សមាជិកទាំងអស់ ។

**២.៨- ប្រព្រឹត្តិកម្មលើប័ណ្ណដែលបាត់**

នៅពេលសមាជិក (ACQ) ទទួលបានសំណើសម្រាប់ដោះស្រាយបញ្ហាប័ណ្ណពីអ្នកកាន់ប័ណ្ណរបស់សមាជិកដទៃ ACQ មិនត្រូវទទួលយកសំណើនេះឡើយ ហើយជូនដំណឹងដល់អ្នកកាន់ប័ណ្ណធ្វើការស្នើសុំដោយផ្ទាល់ទៅ ISS ។

